ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៣៧
ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩

សាលដីកា
លេខ: ៥៤ "V"
ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា
## នាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.លោក [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោក [redacted] ចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

**ដើម្បីជំនុំជម្រះ**

លើបណ្ដឹងសាទុក្ខលេខ២១២ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ របស់លោក[redacted]ឡាយ ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ[redacted]សុខ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៣៦ ក្រIII "វ" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន ៖

**- ជនជាប់ចោទ ៖**

១-ឈ្មោះ[redacted]សុក ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរឃោធា កើតនៅភូមិព្នៅ ឃុំព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នភូមិ[redacted]ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ[redacted]"ស" ម្ដាយឈ្មោះ[redacted]"វ" ប្រពន្ធឈ្មោះ[redacted]មានកូន០៦នាក់ ទោសពីមុនគ្មាន ។ (អ្នកប្ដឹងសាទុក្ខ)



Scanned with CamScanner

-ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ១២៤ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ។

-មានលោកស្រី [redacted] សុវ៉ន ជាមេធាវីការពាសិទ្ធិ ។

២-ឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ កើតនៅភូមិក្រោលគោ ឃុំស្វាយជ្រុំ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ១២៦ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ។

៣-ឈ្មោះ [redacted] សុផា ហៅ យុក ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] រ៉ែម (រ) នៅលីវ ទោសពីមុនគ្មាន ។

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ១៣០ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ។

៤-ឈ្មោះ [redacted] វ៉ាំរុធ ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ កើតនៅភូមិស្រះចក ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខៈ ១២៧ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ។

៥-ឈ្មោះ [redacted] សារឿន ហៅ អៀច ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរជាងម៉ូតូ កើតនៅភូមិស្រះចក ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន ។

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ១២៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ។

៦-ឈ្មោះ [redacted] ស៊ីវុត្ថា ហៅ ម៉ៅ ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស កើត និងទីលំនៅសព្វថ្ងៃ នៅ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ទោសពីមុនគ្មាន ។

៧-ឈ្មោះ [redacted] ហៅ ពយ ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរយោធា កើត និងទីលំនៅសព្វថ្ងៃ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) នៅលីវទោសពីមុនគ្មាន។

**ជាប់ចោទពីបទៈ** មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

Scanned with CamScanner

៨-ឈ្មោះ [redacted] អំភុន ហៅ ឈួយ ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ កើត និងទីលំនៅសព្វថ្ងៃ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។

៩-ឈ្មោះ [redacted] រ័ត្ន ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ កើត និងទីលំនៅសព្វថ្ងៃ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

១០-ឈ្មោះ [redacted] ចាន់ថុល ហៅ បូរី ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ មុខរបរកម្មកររោងចក្រ កើតនៅភូមិឈើទាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងទីលំនៅសព្វថ្ងៃ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

១១-ឈ្មោះ [redacted] អឿន ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ និងរត់ម៉ូតូឌុប កើត និងទីលំនៅសព្វថ្ងៃ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ទោសពីមុនគ្មាន ។

១២-ឈ្មោះ [redacted] ភីរម្យ ហៅ គ្រំ ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើត និងទីលំនៅសព្វថ្ងៃនៅ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

១៣-ឈ្មោះ [redacted] គ្រឿន ហៅ ទូច ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ កើត និងទីលំនៅសព្វថ្ងៃ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

**ជាប់ចោទពីបទ** បង្ករបួសដោយចេតនា ប្រព្រឹត្តនៅភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**-ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] យ៉េង ភេទប្រុស អាយុ៥៤ឆ្នាំ ជាឪពុកជនរងគ្រោះ ដែលបានទទួលមរណភាពឈ្មោះ [redacted] ផល្លា ហៅ ខ្លុយ ។ (ចុងបណ្តឹងសាទុក្ខ)

**-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] ប ភេទស្រី អាយុ៤៧ឆ្នាំ ។

**-អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី** ឈ្មោះ [redacted] គីម អាយុ៣៧ឆ្នាំ និងឈ្មោះ [redacted] ផង់ អាយុ៣៨ឆ្នាំ ទីលំនៅសព្វថ្ងៃ [redacted] ខេត្តកំពង់ឆ្នាំង ជាឪពុកម្តាយជនជាប់ចោទឈ្មោះ [redacted] រ័ត្ន ។

**អំពីអង្គហេតុ ៖**

កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ នៅចំណុចកងពលលេខ ១ មានកម្មវិធីរាំលេងកំសាន្ត ដោយមានការចូលរួមពីប្រជាពលរដ្ឋជាច្រើន ក្នុងនោះមានភូមិស្ពានពោធិ៍ មានឈ្មោះ [redacted] អំភុន, ឈ្មោះ [redacted] រ័ត្ន, ឈ្មោះ [redacted] ចាន់ថុល,



Scanned with CamScanner

ឈ្មោះ [redacted] អឿន,ឈ្មោះ [redacted] ភីរម្យ, ឈ្មោះ [redacted] ផល្លា និងឈ្មោះ [redacted] គឿន និងក្រុមភូមិឧកញ៉ាប៉ាង មានឈ្មោះ [redacted] សុក (ជាអ្នកលក់គ្រឿងក្លែមមុខបន្ទាយ), ឈ្មោះ [redacted] សារឿន, ឈ្មោះ [redacted] វណ្ណា, ឈ្មោះ [redacted] សុផា, ឈ្មោះ [redacted] កុសល, ឈ្មោះ [redacted] ស៊ីវុត្ថា, ឈ្មោះ [redacted] រ៉ាវី,ឈ្មោះ [redacted] វ៉ាន់ថា និងឈ្មោះ [redacted] រ៉ាវុធ ចូលរួមផងដែរ ។ ពេលកំពុងរាំលេង ឈ្មោះ [redacted] សារឿន បានចូលវាយក្រុមស្ពានពោធិ៍ មានឈ្មោះ [redacted] អំតុន, ឈ្មោះ [redacted] រ័ត្ន និងឈ្មោះ [redacted] ភិរម្យ បណ្តាលឱ្យមានរបួស ហើយមានការវាយតបតគ្នា ។ បន្ទាប់ពីកម្មវិធីរាំលេងត្រូវបានបិទ ក្រុមរបស់ឈ្មោះ [redacted] សុក បានរៀបចំឥវ៉ាន់ត្រឡប់មកផ្ទះវិញ ពេលធ្វើដំណើរមកដល់ចំណុចផ្លូវកែង ផ្លូវជាតិលេខប្រាំ ស្រាប់តែក្រុមស្ពានពោធិ៍ដែលបានពួនស្ទាក់ បានគប់ដុំថ្ម វាយ និងកាប់ទៅលើឈ្មោះ [redacted] សុក បណ្តាលឱ្យឈ្មោះ [redacted] ស ជាប្រពន្ធរបស់ឈ្មោះ [redacted] សុក រងរបួសធ្ងន់ធ្ងរជាទម្ងន់ដោយសារគេកាប់ ។ បន្ទាប់មកក្រុមរបស់ឈ្មោះ [redacted] សុក បានវាយតបតវិញ បណ្តាលឱ្យក្រុមស្ពានពោធិ៍ ម្នាក់ ឈ្មោះ [redacted] ផល្លា បានរងគ្រោះរហូតដល់ស្លាប់ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៦៨ (គ) ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ដែលមានខ្លឹមសារដូចតទៅ៖

១-ផ្តន្ទាទោសជនជាប់ចោទ៖

១.១-ឈ្មោះ [redacted] អំតុន ភេទប្រុស អាយុ២០ឆ្នាំ ដាក់ពន្ធនាគារចំនួន ៣(បី)ឆ្នាំ ដោយគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ។

១.២-ឈ្មោះ [redacted] រ័ត្ន ភេទប្រុស អាយុ១៧ឆ្នាំ ដាក់ពន្ធនាគារចំនួន១៨ខែ (ដប់ប្រាំបី)ខែ ដោយគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ។

១.៣-ឈ្មោះ [redacted] ចាន់ថុន ភេទប្រុស អាយុ២៤ឆ្នាំ ដាក់ពន្ធនាគារចំនួន ៣ (បី)ឆ្នាំ ដោយគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ។

១.៤-ឈ្មោះ [redacted] អឿន ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារចំនួន ៣(បី)ឆ្នាំ ដោយគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ។

១.៥-ឈ្មោះ [redacted] ភីរម្យ ភេទប្រុស អាយុ២០ឆ្នាំ ដាក់ពន្ធនាគារចំនួន ៣(បី)ឆ្នាំ ។

១.៦-ឈ្មោះ [redacted] គឿន ភេទប្រុស អាយុ២៤ឆ្នាំ ដាក់ពន្ធនាគារចំនួន ៣(បី)ឆ្នាំ ។

ពីបទៈ បង្ករបួសដោយចេតនា ប្រព្រឹត្តនៅភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១.៧-ឈ្មោះ [redacted] សុក ភេទប្រុស អាយុ ៤៨ឆ្នាំ ដាក់ពន្ធនាគារចំនួន ១០(ដប់)ឆ្នាំ ។

១.៨-ឈ្មោះ [redacted] សារឿន ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារចំនួន ១០(ដប់)ឆ្នាំ ។

១.៩-ឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ ២១ឆ្នាំ ដាក់ពន្ធនាគារចំនួន ១០(ដប់)ឆ្នាំ ។

១.១០-ឈ្មោះ [redacted] រ៉ាវុធ ភេទប្រុស អាយុ ២៣ឆ្នាំ ដាក់ពន្ធនាគារចំនួន១០ (ដប់)ឆ្នាំ ។

១.១១-ឈ្មោះ [redacted] កុសល ភេទប្រុស អាយុ ២០ឆ្នាំ ដាក់ពន្ធនាគារចំនួន ១០(ដប់)ឆ្នាំ ។

Scanned with CamScanner

១.១២-ឈ្មោះ [redacted] ស៊ីវុត្ថា ភេទប្រុស អាយុ ១៩ឆ្នាំ ដាក់ពន្ធនាគារចំនួន ១០(ដប់)ឆ្នាំ ។

១.១៣-ឈ្មោះ [redacted] សុផា ភេទប្រុស អាយុ ២១ឆ្នាំ ដាក់ពន្ធនាគារចំនួន ១០(ដប់)ឆ្នាំ ។

ពីបទៈ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-បង្គាប់ឱ្យជនជាប់ចោទ

២.១-ឈ្មោះ [redacted] អំតុន ។

២.២-អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឈ្មោះ [redacted] គីម និងឈ្មោះ [redacted] ផង់ ជាឪពុកម្តាយរបស់ឈ្មោះ [redacted] រ័ត្ន ។

២.៣-ឈ្មោះ [redacted] ចាន់ថុន ។

២.៤-ឈ្មោះ [redacted] អឿន ។

២.៥-ឈ្មោះ [redacted] ភីរម្យ ។

២.៦-ឈ្មោះ [redacted] គឿន ។

សងសំណងថ្លៃថ្នាំព្យាបាល និងជម្ងឺចិត្តក្នុងម្នាក់ៗចំនួន ១,៥០០,០០០ (មួយលានប្រាំសិបម៉ឺន)រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស ។

២.៧-ឈ្មោះ [redacted] សុក ។

២.៨-ឈ្មោះ [redacted] សារឿន ។

២.៩-ឈ្មោះ [redacted] វណ្ណា ។

២.១០-ឈ្មោះ [redacted] រ៉ាវុធ ។

២.១១-ឈ្មោះ [redacted] កុសល ។

២.១២-ឈ្មោះ [redacted] ស៊ីវុត្ថា ។

២.១៣-ឈ្មោះ [redacted] សុផា ។

សងសំណងជម្ងឺចិត្តក្នុងម្នាក់ៗចំនួន ២,៥០០,០០០(ពីរលានប្រាំសិបម៉ឺន)រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យ៉េង ។

ការទាមទារលើសពីនេះត្រូវច្រានចោល ។

៣-បង្គាប់ឱ្យអាជ្ញាធរមានសមត្ថកិច្ចចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] អំតុន, [redacted] រ័ត្ន, [redacted] ចាន់ថុន, [redacted] អឿន, [redacted] ភីរម្យ, [redacted] សុក, [redacted] សារឿន, [redacted] វណ្ណា, [redacted] រ៉ាវុធ, [redacted] កុសល, [redacted] ស៊ីវុត្ថា និង [redacted] សុផា ។

៤-វត្ថុតាងមាន កាំបិតប៉ុងតោ១, ដំបងឫស្សីប្រឡាក់ឈាម២, ដំបងមែកប្រេងខ្យល់១, ដំបងឈើខ្លុងត្បែង៤, ស្បែកជើង៧ សម្រាប់ និងផ្តេចប១ ត្រូវរឹបអូសបំផ្លាញចោល ។

៥-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គឿន, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] អំតុន, [redacted]



Scanned with CamScanner

វ័ត្ត, [redacted] ចាន់ថុន, [redacted] អឿន, [redacted] ភីរម្យ, [redacted] សុក, [redacted] សាវឿន, [redacted] វណ្ណា, [redacted] រ៉ាវុធ, [redacted] កុសល, [redacted] ស៊ីវុត្ថា និង [redacted] សុផា, កំបាំងមុខអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឈ្មោះ [redacted] គឹម និងឈ្មោះ [redacted] ផង់, ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស និងឈ្មោះ [redacted] យ៉េង ។

បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៥ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] សុក, [redacted] រ៉ាវុធ, [redacted] វណ្ណា, [redacted] សុផា, [redacted] សាវឿន និងដើមបណ្តឹងរដ្ឋប្បវេណី [redacted] ស ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៦៨ (គ) ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌ៣៦ ក្រIII "វ" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] សុផា, ឈ្មោះ [redacted] រ៉ាវុធ , ឈ្មោះ [redacted] សាវឿន, ឈ្មោះ [redacted] វណ្ណា, ឈ្មោះ [redacted] សុក និងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៨ "គ" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ទុកជាបានការ លើកលែងតែ បទចោទប្រកាន់ត្រូវកែប្រែមកបទ ឃាតកម្ម ដែលត្រូវផ្តន្ទាទោសតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌវិញ ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

-សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស, កំបាំងមុខជនជាប់ចោទ ។

-បើកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ៦១២ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ របស់លោក [redacted] ឡាយ ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] សុក ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៣៦ ក្រIII "វ" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ត្រង់សេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានថា៖

- យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុក មិនបានដាក់សារណាមកកាន់តុលាការកំពូលទេ ។ ដូចនេះ តាមមាត្រា ៤២៧ និងមាត្រា ៤៣៦ មិនមានមូលហេតុនាំឲ្យតុលាការកំពូលពិចារណាដូចក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។



Scanned with CamScanner

តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សា ជំនុំជម្រះសម្រេច៖

១-ទទួលបណ្តឹងសាទុក្ខលេខ ២១២ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ របស់លោក [redacted]ឡាយ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សុក ទុកត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធ ដោយខុសទៅនឹងគតិច្បាប់ ។

២-តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ៣៦ “ក្រ.III.វ” ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យ៉េត ភេទប្រុស អាយុ៥៤ឆ្នាំ ជាឪពុករបស់ជនរងគ្រោះ បានសំណូមពរប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេច សុំសងជាសំណង ១៧ លាន កន្លះ ។

លោកស្រី [redacted] សុវ៉ន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សុក បានធ្វើសេចក្តីសន្និដ្ឋានថា ៖ នៅកងពលមានការជួបជុំ រាំលេងកំសាន្ត ហើយនៅក្នុងកម្មវិធីមានក្រុមជនរងគ្រោះ និងក្រុម [redacted] សុក ដោយ [redacted] សុក ជាអ្នកលក់គ្រឿងក្លែម ហើយនៅក្នុងកម្មវិធីនោះក៏មានការរាំរែក ពេលនោះក្រុមស្ពានពោធិ៍ ក៏មានជម្លោះជាមួយក្រុមឧកញ៉ាប៉ាង មិនមែនជម្លោះជាមួយ [redacted] សុក ទេ ។ នៅពេលដែលមានជម្លោះវ៉ៃតប់គ្នា និងបង្កឱ្យមានរបួសស្នាមបន្តិចបន្តួចក៏បែកគ្នាទៅ នៅម៉ោង១២យប់ ក៏បានចប់សព្វគ្រប់ហើយក្រុមខាងស្ពានពោធិ៍ ក៏បានធ្វើដំណើរទៅមុនឯក្រុមខាង [redacted] សុក ក៏បានរៀបអីវ៉ាន់ដាក់រ៉ឺម៉កដោយមានម៉ូតូ សណ្តោងដើម្បីទៅផ្ទះ ។ នៅក្នុងកំណត់ហេតុចៅក្រមស៊ើបសួរ ជនជាប់ចោទឈ្មោះ [redacted] ចាន់ថុល បានឆ្លើយយ៉ាងច្បាស់នៅក្នុងសារណាថា ក្រុមខាងស្ពានពោធិ៍ ក្រោយពេលមានជម្លោះ បង្ករបួសស្នាម ក្រោយរាំរែក គាត់មានកំហឹង គាត់ក៏រៀបចំគម្រោង ដើម្បីសងសឹកទៅក្រុមឧកញ៉ាប៉ាងហើយនៅពេលធ្វើសកម្មភាពមានខ្លួន និងជនរងគ្រោះ បានរៀបគម្រោង មានកាំបិត ដុំថ្ម ដំបងឬស្សី នឹងទៅពួកស្ទាក់ចាំដើម្បីវៃប្រហាទៅលើក្រុមឧកញ៉ាប៉ាងដោយ ក្រុមឧកញ៉ាប៉ាងមានជនជាប់ចោទឈ្មោះ [redacted]សុក នៅក្នុងនោះដែរ ហើយ [redacted] សុក ពុំមានសកម្មភាពអ្វីទាំងអស់ ពីព្រោះពេលនោះគាត់ធ្វើ ដំណើរតាមម៉ូតូសណ្តោងរ៉ឺម៉កដោយមានគ្នា៦នាក់ មានក្មួយ៥នាក់ និងប្រពន្ធ១ ដោយ [redacted] សុក ជាអ្នកបើកម៉ូតូ សណ្តោង ដោយមានដឹកអីវ៉ាន់គ្រឿងក្លែម មានសាច់ មានប៊ីយ៉ែ ពេញខាងក្រោយរ៉ឺម៉ក ពេលទៅដល់កន្លែង កើតហេតុ គាត់ឃើញក្រុមក្មេងៗដែលជាក្រុមស្ពានពោធិ៍ មានដំបង មានកាំបិត មានដុំថ្ម គប់សំដៅមក [redacted] សុក កំពុងធ្វើដំណើរ ដោយពេលនោះប្រពន្ធគាត់ក៏ត្រូវក្មេងៗនោះកាប់១កាំបិត របួសធ្ងន់នៅថ្ពាស់ខាងមុខ ហើយក្មួយៗក៏ត្រូវ របួសដោយសាដុំថ្មដែរ ។ នៅក្នុងរឿងហេតុនេះឃើញថា កើតឡើងពីក្រុមស្ពានពោធិ៍ ដែលរៀបចំជាមុនដើម្បីសងសឹកមកលើក្រុមឧកញ៉ាប៉ាង ហើយការធ្វើកោសល្យវិច័យទៅលើជនរងគ្រោះឈ្មោះ [redacted] ផល្លា លទ្ធផលកោសល្យវិច័យថា ជនរងគ្រោះស្លាប់ដោយត្រូវនិងដុំថ្មគប់ ក្នុងពេលកើតហេតុមានការគប់ទៅមក មិនដឹងថាជនរងគ្រោះ ស្លាប់ដោយក្រុមខ្លួនឯងគប់ច្រឡំក៏ថាបាន ។ យោងតាមអង្គច្បាប់ សេចក្តីសម្រេចរបស់សាលាដំបូងដំណាក់កាលទី១ មិនមែនជា [redacted] សុក ទេ ។ សាលក្រមលើកទី២ បានមានការពាក់ព័ន្ធជាមួយ [redacted] សុក ហើយមកដល់សាលាឧទ្ធរណ៍ ក៏បានសម្រេចតាមសាលាដំបូង សម្រេចចោទប្រកាន់ជនជាប់ចោទ [redacted] សុក ពីបទមនុស្សឃាតដោយចេតនា ពុំមានភស្តុតាង



Scanned with CamScanner

គ្រប់គ្រាន់ ដោយសុទ្ធតែជាការស្មានទាំងអស់ សូមក្រុមប្រឹក្សាពិចារណាទៅលើសំណុំរឿង ឃើញថាគ្មានភស្តុតាងណាមួយបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] សុត បានប្រព្រឹត្តហើយដាក់ទោសជនជាប់ចោទដល់ទៅ១០ឆ្នាំ ។

សំណូមពរ ស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តា ពិចារណាទៅបញ្ហាអង្គច្បាប់ឡើងវិញ សូមក្រុមប្រឹក្សាឲ្យកូនក្ដីនាងខ្ញុំរួចផុតពីបទចោទប្រកាន់ ។

-ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធឲ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១.យល់ឃើញថា បណ្ដឹងសាទុក្ខលេខ២១២ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ របស់លោក [redacted] ឡាយ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុត ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.យល់ឃើញថា សភាព្រហ្មទណ្ឌតុលាការកំពូល បានចេញលិខិតជូនដំណឹងអំពីការចុះបញ្ជីសំណុំរឿង និងឲ្យដាក់សារណាការពារចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ បង្គាប់ឲ្យឈ្មោះ [redacted] សុត ដាក់សារណាការពាររួចហើយ ប៉ុន្តែឈ្មោះនេះ មិនធ្វើសារណាការពាររបស់ខ្លួន ដាក់ជូនមកតុលាការកំពូលតាមកំណត់ច្បាប់ទេ ។ ដូច្នេះ អនុលោមតាមស្មារតីមាត្រា៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលមិនអាចសម្រេច លើកបញ្ហាច្បាប់ដែលអ្នកប្ដឹងសាទុក្ខមិនរៀបរាប់ នៅក្នុងសារណាការពាររបស់ខ្លួននោះទេ ។ ប៉ុន្តែទោះបីជាអ្នកប្ដឹងសាទុក្ខ មិនបានធ្វើសារណាដាក់ជូនមកតុលាការកំពូល ក៏ដោយ ក៏តុលាការកំពូលធ្វើការកត់សម្គាល់ឃើញថា សេចក្ដីសម្រេចរបស់តុលាការអង្គសេចក្ដី មានអង្គហេតុ និងអង្គច្បាប់ត្រឹមត្រូវ ។

៣-យល់ឃើញថា តុលាការកំពូលបានកោះហៅឲ្យឈ្មោះ [redacted] សុត មកចូលរួមសវនាការនេះហើយ ប៉ុន្តែឈ្មោះនេះមិនបានមកចូលរួមទេ តែមេធាវីការពារឲ្យឈ្មោះ [redacted] សុត មានវត្តមាន ។ ដូចនេះ យោងតាមស្មារតីមាត្រា ៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចលើករឿងជំនុំជម្រះបាន ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៣៦ ក្រIII "ទ" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍រាជធានីភ្នំពេញ ដែលបានសម្រេចសេចក្ដីមកនេះត្រឹមត្រូវតាមច្បាប់ ។

## ហេតុដូច្នេះ

## សម្រេច

១.បដិសេធ បណ្ដឹងសាទុក្ខលេខ២១២ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ របស់លោក [redacted] ឡាយ មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] សុត ។

Scanned with CamScanner

២.តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ៣៦ ក្រIII “វ” ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍រាជធានីភ្នំពេញ ទុកជាបានការទាំងមូល ។

សាលដីកានេះ បានជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ និង ប្រកាសសវនាការជាសាធារណៈ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

Scanned with CamScanner